ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**ធនាគារជាតិ នៃ កម្ពុជា**

លេខ ធ.ជ.ក: ០១៧-៣២៤ ប្រ.ក

# ប្រកាស
# ស្តីពី
# លក្ខណៈសម្គាល់នៃធនប័ត្រ ប្រភេទ ៥០០០ រៀល គំរូថ្មី

************

អនុលោមតាមអនុក្រឹត្យលេខ ១៨៤ អនក្រ.បក របស់រាជរដ្ឋាភិបាល ចុះថ្ងៃទី២៥ ខែតុលា ឆ្នាំ ២០១៧ ស្តីពីការចេញផ្សាយធនប័ត្រប្រភេទ ៥០០០ រៀល គំរូថ្មី ក្នុងព្រះរាជាណាចក្រកម្ពុជា ធនាគារជាតិនៃកម្ពុជា សូមប្រកាសផ្សាយជាសាធារណៈ នូវលក្ខណៈសំគាល់នៃធនប័ត្រគំរូថ្មីនេះ មានដូចខាងក្រោម ៖

**ក- លក្ខណៈទូទៅ ៖**

- ទំហំធនប័ត្រ ៖ បណ្តោយ ១៤២ មម និងទទឹង ៦៨ មម
- ពណ៌ចម្បង គឺពណ៌ស្វាយ និងពណ៌ត្នោត ។

**ខ- ផ្ទៃខាងមុខនៃធនប័ត្រ ៖**

**- ផ្នែកកណ្តាល** ខាងស្តាំត្រូវបានរំលេចឡើងនូវព្រះឆាយាល័ក្ខណ៍នៃ **ព្រះបរមរតនកោដ្ឋ ព្រះបាទនរោត្តមសីហនុវរ្ម័ន** កាលពីព្រះអង្គនៅកំពុងបំពេញព្រះរាជបូជនីយកិច្ច ដឹកនាំចលនាតស៊ូទាមទារឯករាជ្យជាតិពីពួកអាណានិគមនិយមបារាំងសេស ខាងឆ្វេងមានលេខ " ៥០០០ " នៅពីលើគេ បន្ទាប់មកគឺជាហត្ថលេខារបស់ទេសាភិបាលនិងអគ្គបេឡា ព្រមទាំងរូបភាពតែងលំអយកតាមរូបក្បាច់ហោជាងនៃអគារតុលាការកំពូល និងនៅពីក្រោមនោះមានលេខ-មាលាបោះពុម្ពដោយទឹកខ្មៅពណ៌ខ្មៅ រូបចម្លាក់នាគក្បាល ៥ នៅវិមានឯករាជ្យ និងអក្សរ "ប្រាំពាន់រៀល" ព្រមទាំងអក្សរ "អ្នកក្លែងក្រដាសប្រាក់នឹងត្រូវផ្តន្ទាទោសតាមច្បាប់" នៅគែមខាងក្រោមនោះ ។

**- ផ្នែកខាងស្តាំ** ជ្រុងលើមានអក្សរ "ធនាគារជាតិនៃកម្ពុជា" ព្រមទាំងលេខ-មាលាបោះពុម្ពដោយទឹកខ្មៅពណ៌ក្រហម នៅកណ្តាលមានរូបភាពអង្គដៅចំណាំខាងមុខ ដែលមើលឆ្លុះឃើញលេខ " 5000 " និងជ្រុងក្រោមមានលេខ " ៥០០០ " ព្រមជាមួយលេខ "5000" នៅពីក្រោមនោះ ។

**- ផ្នែកខាងឆ្វេង** មានលេខ"5000" ព្រាលៗបោះពុម្ពតាមបន្ទាត់បញ្ឈរ ព្រមទាំងរូបភាពតែងលំអពណ៌ប្រាក់យកលំនាំតាមក្បាច់ចម្លាក់នៅប្រាសាទបន្ទាយស្រី បោះពុម្ពកាត់ទទឹងក្រដាស

ប្រាក់ពីលើដល់ក្រោម និងជ្រុងក្រោមមាននិមិត្តសញ្ញាសម្គាល់ប្រភេទប្រាក់សម្រាប់ជនពិការភ្នែក ព្រមទាំងមានគំនូសបន្ទាត់ខ្លីៗជាច្រើនបង្កើតឡើងដោយលេខ " ៥០០០ " ដ៏តូចល្អិត ។

**គ- ផ្ទៃខាងខ្នងនៃធនប័ត្រ ៖**

**- ផ្នែកកណ្តាល** ត្រូវបានរំលេចឡើងនូវរូបភាពនាគក្បាល៩ នៅស្ពានបុរាណកំពង់ក្តី និងរូបតូស្ពានមើលបញ្ឆិតពីចំហៀងខាងស្តាំ នៅពីលើរូបស្ពានមានតែងលំអដោយក្បាច់ចម្លាក់នៅប្រាសាទបន្ទាយស្រី និងនៅពីក្រោមមានអក្សរ " ប្រាំពាន់រៀល " ។

**- ផ្នែកខាងស្តាំ** ជ្រុងលើមានលេខ"5000" បោះពុម្ពតាមបន្ទាត់បញ្ឈរ នៅកណ្តាលជារូបចម្លាក់នៅជញ្ជាំងប្រាសាទបាយ័ន និងនៅជ្រុងក្រោមមានលេខ " ៥០០០ " ។

**- ផ្នែកខាងឆ្វេង** ជ្រុងលើមានអក្សរ " ធនាគារជាតិនៃកម្ពុជា " អក្សរ " NATIONAL BANK OF CAMBODIA " និងលេខ " 2015 " នៅកណ្តាលមានរូបភាពព្រាលៗនៃរូបចម្លាក់ព្រះកេសទេវតានៅឯទ្វារជ័យខាងត្បូងនៃប្រាសាទបាយ័ន និងក្បាច់តែងលំអពណ៌ប្រាក់ផ្តុំឡើងដោយលេខ " ៥០០០ " ព្រមទាំងរូបភាពអង្គរដៅចំណាំខាងខ្នងដែលមើលឆ្លុះឃើញលេខ " 5000 " ផ្កាប់ និងនៅជ្រុងក្រោមមានលេខ " ៥០០០ " ។

ចាប់ពីថ្ងៃចេញប្រកាសនេះតទៅ ធនប័ត្រប្រភេទ ៥០០០ រៀល គំរូថ្មី ត្រូវបានដាក់ឲ្យធ្វើចរាចរទន្ទឹមគ្នាជាមួយនឹងធនប័ត្រជាតិប្រភេទផ្សេងៗទៀតដែលត្រូវបានចេញផ្សាយរួចមកហើយ។ សាធារណជនគ្រប់រូបត្រូវពិនិត្យ-សម្គាល់ធនប័ត្រគំរូថ្មីនេះឲ្យបានច្បាស់លាស់ ដើម្បីជៀសវាងការភ័ន្តច្រឡំ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែ តុលា ឆ្នាំ ២០១៧

**ទេសាភិបាល**

**ជា_ចាន់តូ**